ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៨៧/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំត្រីភាគីរវាងកម្ពុជា ថៃ និងចិន ស្តីពីស្ថានភាពបច្ចុប្បន្នរវាងកម្ពុជានិងថៃ

## ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥ ខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន

តបតាមការអញ្ជើញរបស់**ឯកឧត្តម វ៉ាង យី** រដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំត្រីភាគី នៃរដ្ឋមន្ត្រីការបរទេសនិងមន្ត្រីយោធាជាន់ខ្ពស់នៃកម្ពុជា ថៃ និងចិន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥ នៅបឹងហ្វូសៀន (Fuxian Lake) ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

នេះជាលើកទីបីហើយ ដែលប្រទេសចិនបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំត្រីភាគីរវាងកម្ពុជា ថៃ និងចិន ដែលជាការគូសបញ្ជាក់អំពីតួនាទីសកម្ម និងដោយស្ថាបនារបស់ចិន ក្នុងការលើកកម្ពស់កិច្ចសន្ទនា និងការទាក់ទងគ្នាផ្ទាល់ ដើម្បីជួយកាត់បន្ថយកំដៅជម្លោះព្រំដែនកម្ពុជា-ថៃ និងនាំស្ថានការណ៍ឆ្ពោះទៅរកសន្តិភាព។ កិច្ចប្រជុំនេះបានធ្វើឡើងភ្លាមៗ បន្ទាប់ពីកម្ពុជានិងថៃបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំពិសេសគណៈកម្មាធិការព្រំដែនទូទៅ (GBC) លើកទី៣ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ដោយមានការព្រមព្រៀងរវាងភាគីទាំងពីរ លើបទឈប់បាញ់ដែលបានចូលជាធរមាននៅពេលថ្ងៃ នៃថ្ងៃដដែល។

កិច្ចប្រជុំបានគូសបញ្ជាក់ថា អាទិភាពជាបន្ទាន់គឺការធានាឱ្យបានរឹងមាំនូវបទឈប់បាញ់ និងការធានានូវការអនុវត្តឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ ភាគីចិនបានសម្តែងការគាំទ្រចំពោះការប្តេជ្ញាចិត្តរបស់កម្ពុជា និងថៃថានឹងខិតខំប្រឹងប្រែងជាអតិបរិមា ក្នុងគោលដៅធានាបទឈប់បាញ់ឱ្យបានគ្រប់ជ្រុងជ្រោយ និងខ្ជាប់ខ្ជួន សំដៅឈានទៅសន្តិភាពចីរកាល។ កិច្ចប្រជុំបានសង្កត់ធ្ងន់ថា សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំពិសេសគណៈកម្មាធិការព្រំដែនទូទៅលើកទី៣ បម្រើដល់ផលប្រយោជន៍ជាមូលដ្ឋាន និងយូរអង្វែង របស់ប្រជាជននៃប្រទេសទាំងពីរ ហើយរួមចំណែកដល់សន្តិភាព និងស្ថិរភាពក្នុងតំបន់។

ភាគីទាំងបីគាំទ្រដល់ការងាររបស់គណៈកម្មការចម្រុះខ័ណ្ឌសីមាព្រំដែន ស្របតាមសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំពិសេសគណៈកម្មាធិការព្រំដែនទូទៅលើកទី៣។ កិច្ចប្រជុំបានសង្កត់ធ្ងន់ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីជួយសម្រួលដល់ការវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ និងការស្តារជីវភាពរស់នៅ នៅតាមតំបន់ព្រំដែនដែលរងផលប៉ះពាល់។ ក្នុងន័យនេះ ភាគីចិនបានបង្ហាញពីការត្រៀមខ្លួនក្នុងការផ្តល់ជំនួយចាំបាច់ដល់កម្ពុជា និងថៃ ក្នុងការជំរុញការដោះមីនមនុស្សធម៌ តាមរយៈក្រុមការងារចម្រុះសម្របសម្រួល (JCTF) ការដោះមីន, ផ្តល់ជំនួយមនុស្សធម៌ដល់ជនភៀសសឹកនៅតាមតំបន់ព្រំដែនដែលរងផលប៉ះពាល់ និងផ្តល់ការគាំទ្រជាសារវន្ត ដើម្បីធានាដល់ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់ក្រុមអ្នកសង្កេតការណ៍

អាស៊ាន (AOT)។ ប្រទេសទាំងបីក៏បានព្រមព្រៀងគ្នាក្នុងការចាត់វិធានការឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន មានដូចជាឧក្រិដ្ឋកម្មតាមបណ្តាញទូរគមនាគមន៍ និងការបោកប្រាស់តាមបច្ចេកវិទ្យា ដើម្បីការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជនក្នុងតំបន់។

ភាគីទាំងបីបានបញ្ជាក់ជាថ្មីនូវការទទួលខុសត្រូវរួមរបស់ខ្លួន ក្នុងការការពារសន្តិភាព និងស្ថិរភាពក្នុងតំបន់ ដោយកម្ពុជា និងថៃ បានអះអាងឡើងវិញនូវការប្តេជ្ញាចិត្ត ក្នុងការដោះស្រាយវិវាទដោយសន្តិវិធី និងធ្វើកិច្ចសហប្រតិបត្តិការដោះស្រាយបញ្ហាប្រឈមនានាក្នុងតំបន់ ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍។ ភាគីចិនក៏បានអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការបន្តសម្របសម្រួលការកសាងទំនុកចិត្ត និងសន្តិភាពចីរកាលជាមួយនឹងគោលដៅកសាងសហគមន៍ដែលមានអនាគតរួមគ្នា ក្នុងចំណោមប្រទេសជិតខាង។

នៅក្នុងកិច្ចប្រជុំនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងការកោតសរសើរដ៏ជ្រាលជ្រៅចំពោះតួនាទីសកម្មរបស់ប្រទេសចិន ជាពិសេសការដឹកនាំដ៏ច្បាស់លាស់ និងកិច្ចប្រឹងប្រែងផ្ទាល់ខ្លួនរបស់ **ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** ក្នុងការសម្របសម្រួលកិច្ចសន្ទនា និងការពិគ្រោះយោបល់ ដែលបានរួមចំណែកដល់បទឈប់បាញ់ និងលទ្ធផលនៃកិច្ចប្រជុំពិសេសគណៈកម្មាធិការព្រំដែនទូទៅលើកទី៣ នាពេលថ្មីៗនេះ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា អាទិភាពទីមួយគឺការគោរពពេញលេញ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃបទឈប់បាញ់ ដោយសុឆន្ទៈ និងស្មោះត្រង់ ដើម្បីធានាបាននូវភាពឋិតថេរនៃបទឈប់បាញ់នេះ ដែលនឹងជួយកសាងទំនុកចិត្ត កាត់បន្ថយភាពតានតឹង និងការវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានអះអាងជាថ្មីអំពីជំហរ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជា ក្នុងការរក្សាបទឈប់បាញ់ ដើម្បីឱ្យភាគីទាំងពីរអាចឈានឆ្ពោះទៅរកសន្តិភាពចីរកាល កិច្ចសហប្រតិបត្តិការ និងភាពជាអ្នកជិតខាងដ៏ល្អ។

ជាជំហានឆ្ពោះទៅមុខ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីអាទិភាពសំខាន់ៗ ដែលរួមមានការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់របស់ភាគីទាំងពីរ ចំពោះសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំពិសេសគណៈកម្មាធិការព្រំដែនទូទៅលើកទី៣ សន្ធិសញ្ញា និងអនុសញ្ញាដែលនៅជាធរមាន និងកិច្ចព្រមព្រៀងនានាដែលបានធ្វើកន្លងមក។ **ឯកឧត្តម**បានសង្កត់ធ្ងន់ជាពិសេសលើសារៈសំខាន់នៃការថែរក្សា និងគោរពបទឈប់បាញ់ ការធានាដល់ការដោះលែងយោធិនខ្មែរ ១៨នាក់ ដែលត្រូវបានចាប់ឃុំខ្លួន និងការធានាឱ្យប្រជាជនស៊ីវិលបានវិលត្រឡប់ទៅលំនៅឋានក្នុងតំបន់រងគ្រោះ និងប្រកបជីវភាពរស់នៅជាធម្មតា ដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់បន្ថែមពីសារៈសំខាន់នៃការរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនឱ្យបានឆាប់ ដើម្បីបន្តការងារវាស់វែង និងការបោះបង្គោលព្រំដែន, ការជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែងក្នុងក្របខ័ណ្ឌដែលបានព្រមព្រៀងគ្នា, ការពង្រឹងការកសាងទំនុកចិត្តតាមរយៈការទំនាក់ទំនងផ្នែកយោធា និងការទូតឱ្យបានជាប់ប្រចាំ និងការពង្រឹងតួនាទីរបស់ក្រុមអ្នកសង្កេតការណ៍អាស៊ាន។ **ឯកឧត្តម**ក៏បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធីស្របតាមច្បាប់អន្តរជាតិ ដោយសង្កត់ធ្ងន់លើការទទួលខុសត្រូវរួមក្នុងនាមជាប្រទេសជិតខាង ខណៈដែលប្រទេសកម្ពុជា និងថៃ នៅតែជាអ្នកជិតខាងគ្នាអចិន្ត្រៃយ៍ ដើម្បីធានាសន្តិភាព និងស្ថិរភាពចីរកាលសម្រាប់ប្រជាជននៃប្រទេសទាំងពីរ សម្រាប់តំបន់ និងសម្រាប់គ្រួសារអាស៊ាន។ **ឯកឧត្តម**បានលើកទឹកចិត្តចិនឱ្យបន្តតួនាទីស្ថាបនារបស់ខ្លួន ក្នុងការគាំទ្របទឈប់បាញ់ និងសម្របសម្រួលដំណោះស្រាយដ៏ត្រឹមត្រូវ និងយូរអង្វែង។

ក្នុងឱកាសនៃកិច្ចប្រជុំត្រីភាគី នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាការងារទ្វេភាគីជាមួយ**ឯកឧត្តម វ៉ាង យី**។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តចំពោះមិត្តភាពដែកថែបកម្ពុជា-ចិន និងបានឯកភាពគ្នាពង្រឹងបន្ថែមទៀតនូវភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ជំរុញការកសាងសហគមន៍កម្ពុជា-ចិនគ្រប់រដូវកាលជាមួយនឹងអនាគតរួមគ្នាក្នុងយុគសម័យថ្មី។ ភាគីទាំងពីរបានប្តេជ្ញាពង្រឹងការប្រាស្រ័យទាក់ទងជាន់ខ្ពស់ជាទៀងទាត់ និងជំរុញឱ្យកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅលើគ្រប់កម្រិត និងគ្រប់វិស័យ។ ភាគីទាំងពីរក៏បានផ្លាស់ប្តូរយោបល់ស្តីពីបញ្ហាតំបន់ និងអន្តរជាតិ ដែលមានការយកចិត្តទុកដាក់រួមគ្នា ជាពិសេសការវិវត្តចុងក្រោយបំផុតពាក់ព័ន្ធនឹងស្ថានភាពព្រំដែនកម្ពុជា-ថៃ ហើយបានសង្កត់ធ្ងន់លើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការជិតស្និទ្ធដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍរួមគ្នានៅក្នុងតំបន់។ **ឯកឧត្តម វ៉ាង យី** ក៏បានប្រកាសពីការត្រៀមខ្លួនរបស់ចិន ក្នុងការផ្តល់ជំនួយមនុស្សធម៌សម្រាប់តម្រូវការចិញ្ចឹមជីវិតរបស់ជនភៀសសឹកនៅតាមតំបន់ព្រំដែនដែលរងផលប៉ះពាល់ រួមទាំងជំនួយសង្គ្រោះបន្ទាន់ដែលមានតម្លៃ **២០លានយ័ន** សម្រាប់ជនភៀសសឹកក្នុងប្រទេសកម្ពុជា ដោយសារជម្លោះព្រំដែនកម្ពុជា-ថៃថ្មីៗនេះ។

នៅព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាការងារទ្វេភាគីជាមួយ **ឯកឧត្តម** Sihasak Phuangketkeow រដ្ឋមន្ត្រីក្រសួងការបរទេសថៃ។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តចំពោះបទឈប់បាញ់ និងការអនុវត្តពេញលេញនូវសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំពិសេសគណៈកម្មាធិការព្រំដែនទូទៅ (GBC) លើកទី៣ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ដោយសង្កត់ធ្ងន់ទៅលើភាពចាំបាច់នៃការលើកកម្ពស់ទំនាក់ទំនងជិតស្និទ្ធ ការជឿទុកចិត្តគ្នា នឹងការខិតខំប្រឹងប្រែងរួមគ្នាដើម្បីធានាសន្តិភាព សន្តិសុខ និងស្ថិរភាពនៅតាមព្រំដែន។

ថ្ងៃចន្ទ ១០កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥